**NEWS RELEASE**

UNITED NATIONS HUMAN RIGHTS SPECIAL PROCEDURES
SPECIAL RAPPORTEURS, INDEPENDENT EXPERTS & WORKING GROUPS

# កម្ពុជា៖ អ្នកជំនាញ អ.ស.ប ភ្ញាក់ផ្អើលចំពោះរបាយការណ៍អំពីការជំនុំជម្រះក្តីទ្រង់ទ្រាយធំទៅលើសកម្មជន

ទីក្រុងហ្សឺណែវ (២៥ វិច្ឆិកា ២០២០) - នៅថ្ងៃនេះ អ្នកជំនាញសិទ្ធិមនុស្ស អ.ស.ប ប្រចាំកម្ពុជា បានសម្តែងកង្វល់យ៉ាងខ្លាំងអំពីការជំនុំជម្រះក្តីទ្រង់ទ្រាយធំមួយ ដែលនឹងកើតមានទៅលើបុគ្គលមួយចំនួនដែលជាប់ពាក់ព័ន្ធនឹងគណបក្សសង្គ្រោះជាតិកម្ពុជា (CNRP )។

អ្នកស្រី រ៉ូណា ស្មីត អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា បានមានប្រសាសន៍ថា ព័ត៌មានគួរឲ្យទុកចិត្តបានចង្អុលបង្ហាញអំពីការជំនុំជម្រះក្តីជាច្រើនដែលនឹងចាប់ផ្តើមធ្វើនៅថ្ងៃទី២៦ ខែវិច្ឆិកា ដែលយ៉ាងហោចណាស់ក៏មានមនុស្សចំនួន ១១៣ នាក់ ដែរ ដែលត្រូវបានកោះហៅដោយសាលាដំបូងរាជធានីភ្នំពេញ។ មនុស្សជាច្រើននាក់ទៀត ត្រូវបានកោះហៅសម្រាប់ការជំនុំជម្រះក្តីមួយនៅក្នុងខែធ្នូ។

អ្នកទាំងនោះភាគច្រើនប្រឈមនឹងការចោទប្រកាន់ពីបទសមគំនិត និងញុះញង់ បង្កឲ្យមានភាពវឹកវរធ្ងន់ធ្ងរដល់សន្តិសុខសង្គម ជាបទឧក្រិដ្ឋដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគាររហូតដល់ ១០ ឆ្នាំ។

"ការជំនុំជម្រះក្តីទ្រង់ទ្រាយធំទៅលើសកម្មជនគណបក្សសង្គ្រោះជាតិ ទំនងជាកើតចេញពីហេតុផលនយោបាយ ខ្វះមូលដ្ឋានច្បាប់ច្បាស់លាស់ និងជាការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើសិទ្ធិនីតិវិធីត្រឹមត្រូវ ដែលបានបង្កើតឡើងយ៉ាងរឹងមាំ ដោយច្បាប់សិទ្ធិមនុស្សអន្តរជាតិ" អ្នកស្រីស្មីត បានមានប្រសាសន៍ដូច្នេះ ដោយលោកស្រីបានបន្ថែមទៀតថា ដំណើរក្តីរបស់តុលាការ ទំនងជាផ្នែកមួយនៃយុទ្ធសាស្ត្រ បំភិតបំភ័យ និងបំបាក់មុខគូប្រជែងរបស់រដ្ឋាភិបាល។

"នេះមិនមែនជាភាគមួយដាច់ដោយឡែកទេ។ លំហប្រជាពលរដ្ឋ និងប្រជាធិបតេយ្យ នៅកម្ពុជា បានបន្តធ្លាក់ចុះ ហើយមានភ័ស្តុតាងតិចតួច ដែលបង្ហាញពីការបង្រួបបង្រួម និងការផ្សះផ្សានយោបាយ។"

អ្នកជំនាញ អ.ស.ប រូបនេះ បានមានប្រសាសន៍ថា ក្នុងរយៈពេលប៉ុន្មានខែចុងក្រោយនេះ អាជ្ញាធរបានចាត់វិធានការបង្ក្រាបអ្នកទាំងឡាយណាដែលមានទំនាក់ទំនង ជាមួយគណបក្សសង្គ្រោះជាតិ។ ចាប់តាំងពីខែមិថុនា ឆ្នាំ ២០១៩ មក មានមនុស្សជាង ១៥០ នាក់ ដែលមានទំនាក់ទំនងជាមួយគណបក្សសង្គ្រោះជាតិ ត្រូវបានចាប់ខ្លួន និងឃុំខ្លួន ដែលអ្នកទាំងនោះភាគច្រើនប្រឈមនឹងការចោទប្រកាន់ពីបទរៀបចំផែនការផ្តួលរំលំរដ្ឋាភិបាល និងញុះញង់។

អ្នកស្រី ស្មិត មានប្រសាន៍ថា "មនុស្សគ្រប់រូប ត្រូវមានសិទ្ធិមានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ ដើម្បីរៀបចំរឿងក្តីរបស់ខ្លួន"។

អ្នកស្រីបានមានប្រសាសន៍បន្ថែមទៀតថា "ដោយសារបច្ចុប្បន្ន បុគ្គលមួយចំនួនដែលត្រូវបានតុលាការកោះហៅ កំពុងរស់នៅក្រៅប្រទេសកម្ពុជា មានមូលដ្ឋានសមហេតុផល ដែលអាចជឿថា ជនជាប់ចោទមិនមានលទ្ធភាពទទួលបានឯកសារពាក់ព័ន្ធ រួមទាំងសម្ភារភ័ស្តុតាងដោះបន្ទុក ដើម្បីត្រៀមរៀបចំការពារខ្លួនឡើយ"។

អ្នកស្រី ស្មិត បានមានប្រសាសន៍ថា "ខ្ញុំសូមអំពាវនាវឲ្យអាជ្ញាធរបើកឲ្យមានលំហរពលរដ្ឋ ការពារ និងលើកស្ទួយសេរីភាពមូលដ្ឋាន រួមទាំងសិទ្ធិក្នុងការជួបប្រជុំ និងការបញ្ចេញមតិ និងដើម្បីធានាសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ សម្រាប់មនុស្សគ្រប់រូប ដូចដែលបានធានាការពារដោយបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ និងច្បាប់កម្ពុជា។

## ចប់

***អ្នកស្រី រ៉ូណា ស្មិត*** *(ចក្រភពអង់គ្លេស) ត្រូវបានក្រុមប្រឹក្សាសិទ្ធិមនុស្ស អ.ស.ប តែងតាំងជាអ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ក្នុងខែមីនា ឆ្នាំ២០១៥ ។*

*អ្នករាយការណ៍ពិសេស ពួកគាត់គឺជាផ្នែកមួយនៃអ្វីដែលគេស្គាល់ថាជានីតិវិធីពិសេសរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស។ នីតិវិធីពិសេស (ស្ថាប័នដ៏ធំបំផុតមួយនៃអ្នកជំនាញឯករាជ្យ ក្នុងប្រព័ន្ធសិទ្ធិមនុស្ស អ.ស.ប) គឺជាឈ្មោះទូទៅមួយនៃយន្តការឃ្លាំមើល និងស្វែងរកការពិតឯករាជ្យរបស់ក្រុមប្រឹក្សានេះ។ អ្នកកាន់អាណត្តិនីតិវិធីពិសេស គឺជាអ្នកជំនាញឯករាជ្យផ្នែកសិទ្ធិមនុស្ស ដែលក្រុមប្រឹក្សាសិទ្ធិមនុស្សបានតែងតាំងឡើង ដើម្បីធ្វើការងារពាក់ព័ន្ធនឹងស្ថានភាពសិទ្ធិមនុស្សរបស់ប្រទេសមួយជាក់លាក់ ឬពាក់ព័ន្ធនឹងបញ្ហាសិទ្ធិមនុស្សតាមវិស័យនីមួយៗនៅគ្រប់កន្លែងទាំងអស់លើពិភពលោក។ ពួកគាត់មិនមែនជាបុគ្គលិក អ.ស.ប ទេ ហើយធ្វើការងារដោយឯករាជ្យពីរដ្ឋាភិបាល និងអង្គការទាំងឡាយ។ ពួកគាត់បម្រើការងារក្នុងសមត្ថភាពបុគ្គលផ្ទាល់របស់ខ្លួន ហើយមិនទទួលប្រាក់បៀវត្សរ៍លើការងារនេះឡើយ។*

*ពិនិត្យមើលរបាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីកម្ពុជា និងទំព័រហ្វេសប៊ុករបស់អ្នករាយការណ៍ពិសេស សូមចូលទៅកាន់៖*
https://www.facebook.com/SpecialRapporteurCambodia/?modal=admin_todo_tour

*សិទ្ធិមនុស្ស អ.ស.ប ទំព័រប្រទេស៖ ប្រទេសកម្ពុជា*

*សម្រាប់ព័ត៌មានបន្ថែម និងការសាកសួរព័ត៌មានផ្សេងៗ សូមទាក់ទង៖ ណាវីដ អាម៉េត (Naveed Ahmad) (Nahmed@ohchr.org)*

*សម្រាប់**ការសាកសួរព័ត៌មាន**ពាក់ព័ន្ធនឹងអ្នកជំនាញឯករាជ្យដទៃទៀតរបស់អ.ស.ប សូមទាក់ទង៖ លោក ហ្សេរ៉េមី ឡូរ៉ង់ស៍ )Jeremy Laurence) អង្គភាពប្រព័ន្ធផ្សព្វផ្សាយ សិទ្ធិមនុស្ស អ.ស.ប តាមរយៈទូរស័ព្ទលេខ៖ (+៤១ ២២ ៩១៧ ៩៣៨៣ ឬ អ៊ីម៉ែល jlaurence@ohchr.org)*

*សូមស្វែងយល់អំពីក្រុមអ្នកជំនាញសិទ្ធិមនុស្សឯករាជ្យរបស់ អ.ស.ប តាមដានទ្វីតធឺ @UN_SPExperts*

*តើអ្នកមានកង្វល់អំពីពិភពលោកដែលយើងកំពុងរស់នៅមែនទេ?*

***ដូច្នេះ ក្រោកឡើងដើម្បីសិទ្ធិនរណាម្នាក់នៅថ្ងៃនេះ។***

*#Standup4humanrights*